សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ ថ្ងៃ៧ មករា ១៩៧៩ តើជាថ្ងៃវៀតណាមមានធម៌សប្បុរស ជួយរំដោះពលរដ្ឋខ្មែរ ចេញពីការកាប់សម្លាប់ខ្មែរក្រហម ឬជាថ្ងៃវៀតណាម ចូលមកឈ្លានពានប្រទេសកម្ពុជា រំលោភច្បាប់អង្គការសហប្រជាជាតិ ?

www.hoksavann.org

ថ្ងៃទី១០ មករា ២០១៣



រាល់ពេលថ្ងៃ៧មករារៀងរាល់ឆ្នាំ អ្នកនយោបាយខ្មែរតែងតែមានយោបល់ផ្សេងគ្នា អំពីថ្ងៃ៧ មករា ១៩៧៩ ថាតើថ្ងៃនោះ ជាថ្ងៃវៀតណាមចូលមកឈ្លានពានប្រទេសកម្ពុជា ឬជាថ្ងៃវៀតណាមមានធម៌សប្បុរស ជួយរំដោះប្រជាពលរដ្ឋខ្មែរ ពីការកាប់សម្លាប់របស់ពួកខ្មែរក្រហម ។ ជាមួយនេះដែរ យើងសូមស្រាវជ្រាវរកការពិតជាប្រវត្តិសាស្ត្រអំពីបញ្ហានេះ ដើម្បីជាពន្លឺដល់ប្រជាពលរដ្ឋខ្មែរ ព្រោះបញ្ហានេះមានអាថ៌កំបាំងខ្លះ បើវិនិច្ឆ័យតែសកម្មភាពចេញមកពុំអាចឃើញការពិតឡើយ បើពុំពិនិត្យមើលវាំងននដែលបាំងពីក្រោយ ។

នរណាក៏ដឹងថា លោកហូ-ជីមិញមានផែនការយកប្រទេសកម្ពុជានិងប្រទេសលាវធ្វើជាសហព័ន្ធឥណ្ឌូចិន ក្រោមអំណាចខ្លួនជំនួសបារាំង ។ កាលព្រឹត្តិការណ៍ឆ្នាំ១៩៧០ វៀតណាមជាគ្រូបង្ហាត់បង្រៀនខ្មែរក្រហមខាងកងទ័ពនិងខាងនយោបាយ ។ ក្រោយមក វៀតណាមមានទំនាស់ជាមួយខ្មែរក្រហម រហូតដល់ខ្មែរក្រហមចូលទៅលុកលុយប្រទេសវៀតណាម ដោយកម្លាំងទ័ពនៅខេត្តខ្លះរបស់វៀតណាម ជាប់នឹងព្រំប្រទល់ដែនខ្មែរ ។ ចំណែកវៀតណាមដែលមានសហភាពសូវៀតនៅពីក្រោយ ក៏មានទំនាស់ជាមួយនឹងចិនអំពីបញ្ហាព្រំដែន ។ កាលពីដំបូង វៀតណាមគាំទ្រខ្មែរក្រហមយ៉ាងខ្លាំងក្លា ដើម្បីប្រឆាំងនឹងសាធារណរដ្ឋខ្មែរនិងសហរដ្ឋអាមេរិក ។ ដោយការគាំទ្រនេះហើយ បានជាពេលដែលខ្មែរក្រហមកំពុងកាប់សម្លាប់ពលរដ្ឋខ្មែរជាប្រព័ន្ធ លោករដ្ឋមន្ត្រីជាន់ខ្ពស់នៃប្រទេសអង់គ្លេសបានឮដំណឹងនេះ តាមប្រភពជាច្រើន ជាពិសេសតាមអ្នកភៀសខ្លួនខ្មែរ បានស្នើទៅលោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ Kurk Waldheim ឲ្យបង្កើតគណៈកម្មាធិការពិសេសមួយទៅពិនិត្យមើលការរំលោភសិទ្ធិមនុស្សរបស់ខ្មែរក្រហម ។ ពេលនោះសហភាពសូវៀត, វៀតណាម និងប្រទេសសង្គមនិយមពីរបីទៀតបានប្រឆាំងថា នេះជាកិច្ចការផ្ទៃក្នុងរបស់ខ្មែរ ប្រទេសដទៃមិនត្រូវលូកដៃចូលទេ ។ គំនិតគាំទ្រខ្មែរក្រហមនេះក្រោយមកបានប្តូរផ្លាស់ទៅវិញ ដោយពត៌មានកាន់តែច្បាស់ឡើង អំពីខ្មែរក្រហមរំលោភសិទ្ធិមនុស្សពីប្រភពនានា មានអង្គការលើកលែងទោសអន្តរជាតិជាដើម ។ វៀតណាមកែប្រែការគាំទ្រនេះ ដោយខ្មែរក្រហមបានប្រឆាំងនឹងខ្លួន ហើយបានងាកទៅរកចិនកុម្មុយនិស្តវិញ ។ កស្តុតាងរំលោភសិទ្ធិមនុស្សរបស់ខ្មែរក្រហម មានការកាប់សម្លាប់ពលរដ្ឋខ្មែរជាដើម គេសរសេររាប់ពាន់ទំព័រ ។ ពេលនោះលោកអៀង-សារីជារដ្ឋមន្ត្រីក្រសួងការបរទេសរបស់ខ្មែរក្រហម បានអញ្ជើញលោកអគ្គលេខាធិការអង្គការសហប្រជាជាតិមកពិនិត្យផ្ទាល់អំពីពាក្យចោទនេះ ។ ទំនងវៀតណាមគិតថា បើឲ្យខ្មែរក្រហមចេញផុតពីកណ្តាប់ដៃខ្លួន នោះផែនការសហព័ន្ធកុម្មុយនិស្តឥណ្ឌូចិនត្រូវបាត់បង់ ដូច្នេះត្រូវតែផ្តួលរំលំខ្មែរក្រហម ហើយបង្កើតរដ្ឋាភិបាលថ្មីមួយដែលស្ថិតនៅក្រោមអំណាចខ្លួន ដូចជាប្រទេសលាវ ។ ដោយគំនិតនេះហើយ បានជាពេលដែលលោកអគ្គលេខាធិការអង្គការសហប្រជាជាតិមិនទាន់អញ្ជើញទៅកម្ពុជា ឬចាត់តាំងបេសកជនពិសេសមួយឲ្យទៅកម្ពុជា ដើម្បីពិនិត្យមើលការរំលោភសិទ្ធិមនុស្សរបស់ខ្មែរក្រហមផង ស្រាប់តែវៀតណាមដែលមានការគាំទ្រពីសហភាពសូវៀត លើកកងទ័ពចំនួនពីរសែននាក់ចូលមកប្រទេសកម្ពុជា នៅថ្ងៃ៧ មករា ១៩៧៩ ផ្តួលរំលំខ្មែរក្រហមក្នុងពេលនោះទៅ ។ ឆ្លៀតឱកាសនេះ យើងសូមអរគុណលោកបណ្ឌិតឡៅ-ម៉ុងហៃ ដែលបានពោលអំពីរដ្ឋមន្ត្រីម្នាក់នៃប្រទេសអង់គ្លេសស្នើទៅអង្គការសហប្រជាជាតិ ឲ្យទៅពិនិត្យមើលការរំលោភសិទ្ធិមនុស្សរបស់ខ្មែរក្រហម ដែលមានប្រសាសន៍តាមវិទ្យុសម្លេងសហរដ្ឋអាមេរិក ទុកជាបានជួយបំពេញឯកសារការស្រាវជ្រាវរបស់យើង ។

បុព្វហេតុដែលនាំឲ្យវៀតណាមផ្តួលរំលំខ្មែរក្រហមមានអំពី ៖

- ខ្មែរក្រហមបានយកខ្លួនជាសត្រូវ ហើយលំអៀងទៅរកចិន ។
- ចិនកុម្មុយនិស្តពេលនោះ រកាំរកូសជាមួយវៀតណាម ។
- ចិននិងសហភាពសូវៀតក៏សត្រូវនឹងគ្នា ។

ការទាញយកកស្តុតាងមកប៉ុណ្ណេះបញ្ជាក់ថា អង្គការសិទ្ធិមនុស្សនានាមានអង្គការសហប្រជាជាតិជាដើម បំរុងចូលមកពិនិត្យមើលការពិត អំពីការសម្លាប់ពលរដ្ឋរដ្ឋខ្មែររបស់ខ្មែរក្រហម ហើយនិងធ្វើអន្តរាគមន៍បែបណាមួយ តែបែរជាវៀតណាមដែលមានការគាំទ្រពីសហភាពសូវៀត ដែលកាលពីមុនគាំទ្រខ្មែរក្រហម បែរជាផ្តួលរំលំខ្មែរក្រហមមុនអង្គការសហប្រជាជាតិចូលទៅពិនិត្យការពិតទៅវិញ ។

នៅពេលដែលវៀតណាមបានលើកទ័ពផ្តួលរំលំខ្មែរក្រហម ហើយបានតែងតាំងរដ្ឋាភិបាលមួយជំនួសខ្មែរក្រហមប៉ុលពតដែលដួលរលំ អង្គការសហប្រជាជាតិពុំទទួលស្គាល់ឡើយ ថែមទាំងចោទថា វៀតណាមបានឈ្លានពានប្រទេសកម្ពុជា រំលោភច្បាប់អង្គការសហប្រជាជាតិ ។ មិនតែប៉ុណ្ណោះ មានការប្រឆាំងពីចលនាតស៊ូត្រីភាគីខ្មែរផង ។

បើវៀតណាមជួយសង្គ្រោះខ្មែរ ដោយចិត្តបរិសុទ្ធ ចេញពីការកាប់សម្លាប់របស់ពួកខ្មែរក្រហមពិតមែន គួរតែវៀតណាមបន្ទាប់ពីរំដោះហើយ ប្រគល់បញ្ហាខ្មែរនេះទៅឲ្យអង្គការសហប្រជាជាតិដោះស្រាយបន្ត ដោយប្រកាសប្រាប់ពិភពលោកថា វៀតណាមមានទឹកចិត្តអាណិតអាសូរប្រជាពលរដ្ឋខ្មែរ ដែលត្រូវខ្មែរក្រហមសម្លាប់ជាបន្តបន្ទាប់គ្នា បានជាវៀតណាមលើកទ័ពយ៉ាងប្រញាប់ប្រញាល់មករំដោះ ដើម្បីកុំឲ្យខ្មែរស្លាប់តទៅទៀត ។ ឥឡូវនេះចិច្ចការរបស់វៀតណាមបានត្រូវបញ្ចប់ហើយ សូមអង្គការសហប្រជាជាតិយកទ័ពមួកខៀវ មកការពារពលរដ្ឋខ្មែរ ហើយដោះស្រាយឲ្យខ្មែររួបរួមគ្នាឡើងវិញ កុំចោទវៀតណាមថាឈ្លានពានខ្មែរ ។ បើវៀតណាមធ្វើដូច្នេះ ពិភពលោកនិងពលរដ្ឋខ្មែរប្រហែលមិនចោទថា វៀត-ណាមឈ្លានពានខ្មែរឡើយ គឺវៀតណាមពិតជាជួយសង្គ្រោះប្រជាពលរដ្ឋខ្មែរដោយធម៌សប្បុរសពិតប្រាកដមែន ។

ផ្ទុយទៅវិញ បែរជាទៅកាន់កាប់ប្រទេសកម្ពុជា ៖

- ប្រមូលភោគទ្រព្យខ្មែរដឹកទៅប្រទេសខ្លួន ។
- ប្រឆាំងអ្នកស្នេហាជាតិខ្មែរ ចាប់ដាក់គុកនិងសម្លាប់ ។
- បង្កើត «ក-៥» ធ្វើឲ្យពលរដ្ឋខ្មែរស្លាប់អស់កន្លះលាននាក់ ។
- ពុទ្ធសាសនាឲ្យបួសខ្លះ តែបួសពីអាយុ៥០ឡើងទៅ ។
- បង្ខំឲ្យខ្មែរកាន់របបកុម្មុយនិស្តដូចប្រទេសខ្លួន ។
- ធ្វើអាណានិគមនិយមលើប្រទេសកម្ពុជា គ្រប់វេទនាសម្ព័ន្ធទាំងអស់ ។ល។

វៀតណាមបង្ខំចិត្តដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជាកាលពីឆ្នាំ១៩៨៨ ដោយមូលហេតុ ៖

- សហភាពសូវៀត ដែលគាំទ្រខ្លួនទាំងថវិកា ទាំងសេដ្ឋកិច្ច និងនយោបាយបានដួលរលំ ។
- មានសម្ពាធពីអន្តរជាតិ ។

ដោយមានភ្លើងខៀវពីវៀតណាមនេះហើយ បានជាកើតមានការចរចារវាងសម្តេចនរោត្តម-សីហនុនិងលោកហ៊ុន-សែន ដើម្បីរកវិធីដោះស្រាយក្នុងការរួបរួមគ្នានេះ ។ ទីបំផុត ក៏កើតមានកិច្ចព្រមព្រៀងសន្តិភាពប្រទេសកម្ពុជានៅទីក្រុងប៉ារីសប្រទេសបារាំង ដែលមានលោករដ្ឋមន្ត្រីក្រសួងការបរទេសប្រទេសបារាំងនិងឥណ្ឌូណេស៊ីជាសហប្រធាន នៅថ្ងៃទី២១ តុលា ១៩៩១ ។ ការចុះហត្ថលេខាមាន១៩ប្រទេស ដោយរួមទាំងឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់តំណាងខ្មែរផង ។ កិច្ចព្រមព្រៀងនោះមានគោលសំខាន់គឺ ដកកងទ័ពបរទេសទាំងអស់ចេញពីប្រទេសកម្ពុជា, ដកអាវុធចេញពីគ្រប់ភាគីខ្មែរ, បោះឆ្នោតដោយសេរីនិងយុត្តិធម៌ ហើយកសាងប្រទេសកម្ពុជាឡើងវិញ ។ ដូច្នេះកិច្ចព្រមព្រៀងនេះ ជាការធានាពីអន្តរជាតិ ហើយខ្មែរនិងខ្មែរសុខចិត្តដាក់អាវុធ ហើយរួបរួមគ្នាដោះស្រាយបញ្ហាជាតិខ្លួនដោយសន្តិវិធី ។ ដោយកិច្ចព្រមព្រៀងគ្នានេះហើយ បានបង្កើតរដ្ឋធម្មនុញ្ញមួយដែលមានគោលដ៏សំខាន់ថា រាជាណាចក្រកម្ពុជាកាន់របបប្រជាធិបតេយ្យសេរីពហុប-ក្ស ទើបបង្កើតការបោះឆ្នោតឆ្នាំ១៩៩៣ ក្រោមអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ (UNTAC) ។ ពេលនោះ ទោះបីមានបញ្ហាខ្លះជាមួយខ្មែរក្រហម នោះជាបញ្ហាតូចតាចផ្ទៃក្នុងប៉ុណ្ណោះ ។

តាមការរៀបរាប់ខាងលើនេះបានន័យថា វៀតណាមមិនដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជាឡើយ បើខ្មែរក្រហមនៅតែយកខ្លួនជាគ្រូមិនសត្រូវនឹងខ្លួន ហើយសហភាពសូវៀតមិនដួលរលំ ។ ពេលនោះ ទោះបីខ្មែរក្រហមកាប់សម្លាប់ពលរដ្ឋខ្មែរដ៏សាហាវយ៉ាងណាក៏ដោយ ក៏វៀតណាមគ្មានរវល់ឡើយ ព្រោះពេលដែលនៅត្រូវគ្នា វៀតណាមថែមទាំងប្រឆាំងអ្នកដែលរិះគន់ខ្មែរក្រហមថារំលោភសិទ្ធិមនុស្សផង ។ ត្រង់ចំណុចដែលថាការកាប់សម្លាប់នោះ ចេញមកពីបញ្ជាពីអង្គការលើគឺវៀតណាម ត្រង់នេះយើងគ្មានយោបល់ទេ ព្រោះពេលដែលមេខ្មែរក្រហមនួន-ជា, ខៀវ-សំផន, អៀង-សារី នៅក្នុងវង្វង់ក្រចកសេះ ពុំឮពាក្យចោទចំៗដូច្នេះឡើយ ។ ពេលនោះជាកុសលល្អរបស់ខ្មែរ សហភាពសូវៀតត្រូវដួលរលំ ហើយមានសម្ពាធដ៏ខ្លាំងក្លាពីអន្តរជាតិផង វៀតណាមត្រូវបង្ខំចិត្តដកទ័ពចេញពីប្រទេសកម្ពុជា ពុំអាចយកប្រ-ទេសកម្ពុជាបញ្ចូលជាសហព័ន្ធកុម្មុយនិស្តឥណ្ឌូចិនដូចប្រទេសលាវ តាមផែនការរបស់លោកហូ-ជីមិញបានឡើយ ។ តាមការរៀបរាប់មកនេះ ជាពន្ទឺដល់អ្នកអានថា តើវៀតណាមចូលមកកំចាត់ខ្មែរក្រហម មានបំណងសង្គ្រោះពលរដ្ឋខ្មែរពីការកាប់សម្លាប់ ឬប្រយោជន៍យកប្រទេសកម្ពុជាដាក់បញ្ចូលជាសហព័ន្ធកុម្មុយនិស្តឥណ្ឌូចិន នៅក្រោមអំណាចគ្រប់គ្រងរបស់ខ្លួន ។ ផ្ទុយទៅវិញ រាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្នពោលថា ប្រជាពលរដ្ឋខ្មែរបានបង្កើតរណសិរ្សរំដោះជាតិមួយប្រឆាំងខ្មែរក្រហម ហើយពឹងទាហានស្ម័គ្រចិត្តវៀតណាមឲ្យមកជួយ ពុំមែនវៀតណាមឈ្លានពានឡើយ ។

បើធ្វើបុណ្យរំឭកថ្ងៃ៧ មករា ១៩៧៩ ទុកជាការទទួលស្គាល់ថា វៀតណាមចូលមករំដោះប្រជាពលរដ្ឋខ្មែរ ចេញពីការកាប់សម្លាប់របស់ខ្មែរក្រហម ដែលផ្ទុយពីអង្គការសហប្រជាជាតិនិងភាគីជម្លោះខ្មែរដែលចោទថា វៀតណាមចូលមកឈ្លានពានប្រទេសកម្ពុជា ។

បើធ្វើបុណ្យរំឭកថ្ងៃ២៣ តុលា ១៩៩១ ទុកជាការគោរពតាមសន្ធិសញ្ញាអន្តរជាតិ ដែលមានអង្គការសហប្រជាជាតិជាអ្នកធានា និងការព្រមព្រៀងរបស់ខ្មែរគ្រប់ភាគី ។ ជាថ្ងៃបញ្ចប់ការឈ្លានពានពីបរទេស និងជាថ្ងៃផ្សះផ្សាជាតិខ្មែរឡើងវិញ ។

ទីបំផុត យើងសូមអំពាវនាវ សូមឲ្យខ្មែរនិងខ្មែររួបរួមគ្នាទាំងគណបក្សកាន់អំណាច ទាំងគណបក្សប្រឆាំង ដោយបំ-ពេញមុខងារនាទីរៀងខ្លួនតាមច្បាប់ទម្លាប់ដោយសន្តិវិធី ហើយនាំគ្នារក្សាឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីឲ្យគង់វង្ស ។ យើងពុំអាចយកប្រទេសជិតខាងជាសត្រូវរហូតឡើយ ត្រូវយកប្រទេសជិតខាងជាមិត្ត ប៉ុន្តែត្រូវគោរពសិទ្ធិគ្នាទៅវិញទៅមក មិនឈ្លានពានគ្នា ក្នុងឋានៈជាប្រទេសស្ថិតនៅភូមិផងរបងជាមួយ ។៚

*     *

*